**បីថ្ងៃ និង បីយប់** *(ពណ៌ខ្មៅ = យប់ / ពណ៌ស = ថ្ងៃ ។ ១យប់ និង ១ថ្ងៃ = ២៤ ម៉ោង: លោកុប្បត្តិ ១:៥; យ៉ូហាន ១១:៩-១០)*




**THE THREE DAYS AND THREE NIGHTS** (Black = Night time / White = Day time. 1 Night & 1 Day = 24 Hours: Gen. 1:5; John 11:9-10)



# លំដាប់ពេល នៃព្រឹត្តិការណ៍ នៃការសុគត និងការមានព្រះជន្មរស់ឡើងវិញ នៃព្រះយេស៊ូវគ្រីស្ទ

| ថ្ងៃអង្គារ | ថ្ងៃពុធ | ថ្ងៃព្រហស្បតិ៍ | ថ្ងៃសុក្រ | ថ្ងៃសៅរ៍ | ថ្ងៃអាទិត្យ |
|---|---|---|---|---|---|
| ព្រះយេស៊ូបានសោយអាហារនៃបុណ្យរំលង នៅវេលាយប់ជាមួយនឹងពួកសិស្សទ្រង់ ហើយក៏បានតាំងដំណាង នៃ សញ្ញាថ្មី (ម៉ាថាយ ២៦:២៦-២៨)<br><br>បន្ទាប់មកព្រះយេស៊ូត្រូវបានបញ្ជូនដោយយូដាសអ៊ីស្ការីយ៉ុត ហើយបានត្រូវគេចាប់<br><br>រួចហើយនៅវេលាយប់ដដែលនេះ ទ្រង់ត្រូវបានគេនាំទៅនៅចំពោះសម្តេចសង្ឃ ពួកអាចារ្យ និងពួកចាស់ទុំ។ (ម៉ាថាយ ២៦:៥៧) | ព្រះយេស៊ូបានសុគត នៅ វេលាម៉ោង ៣ រសៀល (ម៉ាថាយ ២៧:៤៦-៥០) ។ ថ្ងៃនេះគឺជា «ថ្ងៃរៀបចំ» បុណ្យធំប្រចាំឆ្នាំ មិនមែនជាថ្ងៃឈប់សំរាកប្រចាំសប្តាហ៍នោះទេ ។ «ថ្ងៃបុណ្យធំ» ប្រចាំឆ្នាំនេះ (ក៏ដូចថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ដែរ) គឺត្រូវបានចាប់ផ្តើមនៅពេលថ្ងៃលិច (ម៉ាកុស ១៥:៤៣; លូកា ២៣:៥៤; យ៉ូហាន ១៩:៣១) ។ ព្រះសពព្រះយេស៊ូត្រូវបានគេបញ្ចុះក្នុងផ្នូរ នៅពេលហៀបនឹងថ្ងៃលិច នៅថ្ងៃពុធនេះ (ម៉ាថាយ ២៧:៥៧-៦០) ។ | ថ្ងៃព្រហស្បតិ៍នេះ គឺជាថ្ងៃឈប់សំរាកនៃបុណ្យធំ (យ៉ូហាន ១៩:៣១) គឺជាថ្ងៃទី១ នៃ «ថ្ងៃនំបុ័ងឥតដំបែ» គឺជាថ្ងៃក្រោយបន្ទាប់ពី «ថ្ងៃបុណ្យរំលង» ដែលនៅលេវីវិន័យ ២៣:៥ ថាជា «ថ្ងៃ ១៤ ក្នុងខែ» ។ នៅលេវីវិន័យ ២៣:៦ ថាថ្ងៃនេះជា «ថ្ងៃ ១៥ ក្នុងខែ គឺជាថ្ងៃបុណ្យនំបុ័ងឥតដំបែ» ។ ថ្ងៃនេះត្រូវបានគេហៅថា គឺជាថ្ងៃបន្ទាប់ពី «ថ្ងៃរៀបចំ» នៅគម្ពីរខ្មែរចាស់ប្រែថា: «ក្រោយថ្ងៃរៀបបុណ្យ» (ម៉ាថាយ ២៧:៦២) ។ | ឥឡូវនេះ ថ្ងៃឈប់សំរាកនៃ «បុណ្យធំ» ប្រចាំឆ្នាំ នៅគម្ពីរយ៉ូហាន ១៩:៣១ ក៏បានកន្លងផុតហើយ ។ រីឯពួកស្ត្រីក៏បាននាំគ្នា «<u>ទៅទិញ</u>» ម៉ាកុស ១៦: ១ គ្រឿងក្រអូបសម្រាប់យកទៅអប់ព្រះសពព្រះយេស៊ូ គ្រឿងទាំងនោះត្រូវតែបានរៀបចំទុកឲ្យហើយរួចជាស្រេចឲ្យបានទាន់មុនថ្ងៃឈប់សំរាកប្រចាំសប្តាហ៍មកដល់ ដែលត្រូវចាប់ផ្តើមនៅពេលថ្ងៃលិច គឺជាព្រលប់ (ឬយប់) នៃថ្ងៃសុក្រនេះ ។ (ម៉ាកុស ១៦:១; លូកា ២៣:៥៦) ។ | ពួកស្ត្រីត្រូវតែឈប់សំរាកនៅថ្ងៃនេះ គឺជាថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ តាមក្រឹត្យវិន័យ (លូកា ២៣:៥៦; និក្ខមនំ ២០:៨-១១) ។ ឯព្រះយេស៊ូបានមានព្រះជន្មរស់ឡើងវិញ នៅពេលហៀបនឹងថ្ងៃលិច គឺជាខួបដែលចំនឹងពេលជាគម្រប់ **«៣ ថ្ងៃ ៣ យប់»** **(ម៉ាថាយ ១២:៤០)** ក្រោយពីបាននៅក្នុងផ្នូរ ដែលធ្វើឲ្យសម្រេចតាមសញ្ញានៃលោកព្យាការីយ៉ូណាស ហើយក៏បានបញ្ជាក់នូវសេចក្តីពិត ដែលទ្រង់បានផ្តល់ឲ្យពួកសង្គ្រាជ ថាទ្រង់គឺជាព្រះគ្រីស្ទពិតមែន ។ | នៅពេលព្រលឹមស្រាងនាព្រឹកថ្ងៃអាទិត្យ ពួកស្ត្រីក៏រួសរាន់ឆ្ពោះទៅឯផ្នូរពេលនៅងងឹតនៅឡើយ (លូកា២៤:១; យ៉ូហាន ២០:១) ខណៈនោះ គេក៏ត្រូវបានប្រកាសឲ្យដឹងថា ព្រះយេស៊ូទ្រង់បានមានព្រះជន្មរស់ឡើងវិញរួចជាស្រេចហើយ! (ម៉ាថាយ ២៨:១-៦; ម៉ាកុស ១៦:២-៦; លូកា ២៤:២-៣; យ៉ូហាន ២០:១ ) ។ ទ្រង់មិនរស់ឡើងវិញនៅព្រឹកថ្ងៃអាទិត្យទេ ។ តែផ្ទុយទៅវិញគឺនៅពេលហៀបនឹងថ្ងៃលិច នៅល្ងាចថ្ងៃសៅរ៍ឯណោះវិញទេ!។ |